# តារាងស្ដីពីព័ត៌មានរបស់គម្រោង

លេខPIP : 1235

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ការគ្រប់គ្រងទិន្នន័យកសិកម្មរបស់កសិករ តាមប្រព័ន្ធឌីជីថល

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្ដើមគម្រោង | 01/01/25 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/27 |

៣. ចំណាយគម្រោងសរុប $3,960,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| | |
|---|---|
| RESPONSIBLE UNIT | Agricultural Information and Documentation Center |
| អង្គភាពទទួលខុសត្រូវ | មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម |

៥. ស្ថានភាពគម្រោង គម្រោងដែលបានលុបចោល

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៣- ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ប្រព័ន្ធគ្រប់គ្រងទិន្នន័យកសិកម្ម របស់កសិករ ជាប្រព័ន្ធប្រមូលផ្ដុំព័ត៌មានសំខាន់ៗរបស់កសិករ ដែលទាក់ទងនឹងដំណើរការអនុវត្តកសិកម្ម មានដូចជា៖ ព័ត៌មានផ្ទាល់ខ្លួន ព័ត៌មានភូមិសាស្រ្ត ព័ត៌មានទំហំផលិតកម្ម ព័ត៌មានអំពីអាកាសធាតុ ទិន្នន័យអំពីសត្វល្អិតចង្រៃ/ជំងឺ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងព័ត៌មានទីផ្សារកសិកម្មជាដើម ដែលអាចផ្ដល់ដល់កសិករ សមាគមន៍កសិកម្ម អ្នករៀបចំគោលនយោបាយ ឬអ្នកវិនិយោគទៅលើវិស័យកសិកម្មផ្សេងៗទៀត អាចទាញយកទៅដើម្បីធ្វើការសម្រេចចិត្ត និងធ្វើផែនការដាំដុះ ឬផលិត ផលិតផលណាមួយ ប្រកបដោយប្រសិទ្ធភាព ហើយឆ្លើយតបទៅនឹងតម្រូវការទីផ្សារ (ទាំងបរិមាណ និងគុណភាព) ក្នុងស្រុក ក្នុងតំបន់ និងអន្តរជាតិ។ ម្យ៉ាងវិញទៀត តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់កសិកម្មអាចជួយឲ្យកសិករ និងសហគមន៍កសិកម្ម ដោះស្រាយបញ្ហាប្រឈមនានា ក្នុងដំណើរការផលិតកម្មបានទាន់ពេលវេលា។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

គាំទ្រ

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ ?

**១១. វិស័យ** ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

**កសិកម្ម និងការគ្រប់គ្រងដីធ្លី**

Research and Extension Services
Agriculture
Fisheries
Agriculture
Livestock
Agriculture

**១២. ទីតាំងអនុវត្តគម្រោង** ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

**បន្ទាយមានជ័យ, បាត់ដំបង, សៀមរាប, ពោធិ៍សាត់, ប៉ៃលិន,**

១៣. គោលបំណងរបស់គម្រោង ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

១. គ្រប់គ្រងព័ត៌មានកសិករ សហគមន៍កសិកម្ម អំពីការដាំដុះឱ្យកាន់តែមានប្រសិទ្ធភាព និងទាញយកទិន្នន័យមកប្រើប្រាស់បានងាយស្រួល និងឆាប់រហ័ស
២. ផ្សារភ្ជាប់ទំនាក់ទំនងរវាងអ្នកលក់ អ្នកទិញ អ្នកវិនិយោគលើវិស័យកសិកម្ម ដើម្បីធ្វើការចរចារទិញ លក់ ផ្លាស់ប្តូរបទពិសោធន៍ ផ្តល់យោបល់ ក្នុងវិស័យកសិកម្មតាមបែបឌីជីថល និងតម្រូវការទីផ្សារ
៣. ជួយកសិករក្នុងការទទួលបានព័ត៌មានសំខាន់ៗ សម្រាប់ធ្វើការសម្រេចចិត្តក្នុងការដាំដុះដូចជា ព័ត៌មានតម្លៃទីផ្សារ គ្រប់គ្រងអាកាសធាតុ និងបច្ចេកទេសថ្មីៗ។

**១៤. ការពិពណ៌នាអំពីគម្រោង** ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ សម្រាប់កសិកម្ម ជាប្រភពនៃបណ្ណុំព័ត៌មានសម្រាប់ប្រើប្រាស់ក្នុងការអភិវឌ្ឍវិស័យកសិកម្ម។ ប្រព័ន្ធនេះបានចូលរួមក្នុងការដោះស្រាយរាល់បញ្ហាប្រឈម និងផ្តល់ជាអនុសាសន៍ក្នុង ការធ្វើផែនការ ផលិតកម្ម និងទីផ្សារ ដើម្បីជំរុញវិស័យកសិកម្មឆ្ពោះទៅកាន់ការគ្រប់គ្រងដោយប្រព័ន្ធព័ត៌បច្ចេកវិទ្យាព័ត៌មាន។

មុខងារសំខាន់ៗរបស់កម្មវិធី

១. ការប្រើប្រាស់ដីកសិកម្ម

-ទិន្នន័យកសិករ (Farmer Profile): ព័ត៌មានកសិករជាមួយនឹងប្រភេទដំណាំដែលគាត់ដាំដុះ ទំហំផ្ទៃដីដាំដុះ និងពេលវេលាចាប់ផ្តើមដាំដុះ ដែលអាចប៉ាន់ប្រមាណពេលវេលាប្រមូលផល និងបរិមាណប្រមូលផល រាល់ពេលកសិករចាប់ផ្តើមដាំដំណាំអ្វីមួយ គាត់អាចបញ្ចូលព័ត៌មាន និងដំណើរការនៃការដាំដុះរបស់គាត់ជាមួយនឹងការកំណត់ទីតាំងក្នុងផែនទីដោយប្រើ GPS ក្នុងទូរស័ព្ទដៃរបស់ពួកគាត់

-អ្នកគ្រប់គ្រងអាចតាមដានការប្រើប្រាស់ដីកសិកម្ម និងប្រភេទដំណាំតាមរយៈព័ត៌មានដែលកសិករបានបញ្ចូលខាងលើ

-សាធារណជន អ្នកវិនិយោគ និងដៃគូអភិវឌ្ឍនានា ទទួលបាននូវព័ត៌មានសុក្រឹត និងត្រឹមត្រូវសម្រាប់ធ្វើការអភិវឌ្ឍ។

២. ទីផ្សារកសិផល

-អ្នកទិញផលិផលកសិកម្មអាចប្រើប្រាស់កម្មវិធីនេះ ដើម្បីស្វែងរកកសិករដែលដាំដំណាំដែលគាត់ត្រូវការ និងអាចចរចារក្នុងការកក់ការទិញទុកជាមុនពេលប្រមូលផល

-ផ្តល់ព័ត៌មានដល់កសិករអំពីតម្លៃកសិផលតាមប្រភេទដំណាំ តម្លៃលក់នៅចំការ តម្លៃលក់នៅទីផ្សារលក់ដុំ និងលក់រាយតាមផ្សារសំខាន់ៗ។

៣. មុខងារជំនួយបច្ចេកទេស

មុខងារសម្រាប់ជួយដល់កសិករ ស្វែងរកជំនួយបច្ចេកទេសដែលគាត់ត្រូវការ ឬក្នុងការជួយដោះស្រាយបញ្ហាអ្វីមួយដែលកើតមានឡើងក្នុងអំឡុងពេលការដាំដុះ ឬការចិញ្ចឹមរបស់គាត់។ កម្មវិធីទូរស័ព្ទដៃនេះ នឹងរៀបចំបញ្ចូលលេខទូរស័ព្ទ "សេវាផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ ដែលអាចឲ្យពួកគាត់ទំនាក់ទំនងតាមរយៈលេខ ១២៨៩" ដោយឥតគិតថ្លៃផងដែរ។

៤. ព័ត៌មានអាកាសធាតុ (Weather Broadcasting)

សម្រាប់មុខងារនេះ សាធារណជន ជាពិសេសកសិករអាចដឹងមុនពីព័ត៌មានអាកាសធាតុ និងព្រឹត្តិការណ៍ដែលអាចកើតមានឡើងក្នុងឆ្នាំ ដើម្បីត្រៀមបង្ការ ការពារ ទប់ស្កាត់ និងធ្វើការសម្រេចចិត្តក្នុងការដាំដុះឲ្យបានសមស្រប និងទាន់ពេលវេលា ក្នុងការកាត់បន្ថយហានិភ័យដែលបង្កឱ្យមានផលប៉ះពាល់ក្នុងការបង្កបង្កើនផលរបស់ពួកគាត់បានជាអប្បរមា។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ឆ្នាំ២០២៣-២០២៧ របស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់យុទ្ធសាស្ត្របញ្ចកោណអណត្តិទី១ ដើម្បីរួមចំណែកក្នុងការលើកស្ទួយការអភិវឌ្ឍនវិស័យកសិកម្មឲ្យទាន់ទៅនឹងបរិបទនៃការផ្លាស់ប្តូរសង្គម ការរីកចំរើននៃប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងការបម្រែលបម្រួលអាកាសធាតុ ដូច្នេះ តាមរយៈគម្រោង បង្កើតឲ្យមានជាប្រព័ន្ធគ្រប់គ្រងទិន្នន័យកសិកម្មរបស់កសិករ តាមប្រព័ន្ធឌីជីថល ដើម្បីជំរុញ និងបង្កើនប្រសិទ្ធភាពការងាររបស់អនុវិស័យ និងដៃគូអភិវឌ្ឍន៍ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់មួយកម្រិតទៀត។

ជាពិសេស ជំរុញផលិតកម្មកសិកម្មឲ្យកាន់តែប្រសើរឡើង ឆ្លើយតបទៅនឹងតំរូវការទីផ្សារក្នុងស្រុក ក្នុងតំបន់ និងអន្តរជាតិ ដើម្បីជាការចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ ឈានទៅរកការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជាផងដែរ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

១.បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងព័ត៌មានកសិករ សហគមន៍កសិកម្ម អំពីការដាំដុះ និងផលិត។ ការទាញយកទិន្នន័យមកប្រើប្រាស់នឹងទទួលបាននូវភាពងាយស្រួល និងឆាប់រហ័ស

២.ផ្សាភ្ជាប់ទំនាក់ទំនងកាន់តែជិតស្និតរវាងកសិករ ឬអ្នកផលិត និងអ្នកទិញកសិផល និងមានទំនុកចិត្តខ្ពស់ក្នុងការទិញលក់ផលិតផលលើទីផ្សារ

៣.ផ្តល់ភាពងាយស្រួលដល់កសិករក្នុងការទទួលបាននូវព័ត៌មានសំខាន់ៗ សម្រាប់ធ្វើការសម្រេចចិត្តក្នុងការដាំដុះដូចជាព័ត៌មានតម្លៃទីផ្សារ អាកាសធាតុ និងបច្ចេកទេសថ្មីៗ។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទានចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះនឹងមិនមានផលប៉ះពាល់ដល់ប្រជាជន និងបរិស្ថានជុំវិញទេ ផ្ទុយទៅវិញបានចូលរួមចំណែកជាប្រភពព័ត៌មានសម្រាប់រៀបចំគោលនយោបាយ និងផែនការអភិវឌ្ឍផ្នែកបរិស្ថាន និងសង្គម។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**សម្រាប់គម្រោងនេះនឹងផ្តល់ភាពងាយស្រួលដល់ស្ត្រី និងបង្កើនចំណេះដឹងទាក់ទងនឹងព័ត៌មានវិទ្យាដល់ពួកគាត់ក្នុងការចូលរួមការងារអនុវត្តវិស័យកសិកម្ម ការគ្រប់គ្រងកសិដ្ឋានរបស់ខ្លួនដែលអាចជួយសន្សំពេលវេលា និងកម្លាំងពលកម្មបានច្រើន ហើយព្រមទាំងជួយពួកគាត់ធ្វើការសម្រេចចិត្តបានលឿន និងត្រឹមត្រូវ ក្នុងការផលិត ថាតើគួរផលិតអ្វី ផលិតនៅពេលណា ហើយលក់នៅណាឬអ្នកណាជាអតិថិជនរបស់គាត់?ម្យ៉ាងវិញទៀតតាមរយៈការអនុវត្តគម្រោងនេះនឹងមានការលើកទឹកចិត្ត និងគាំទ្រឲ្យមានការចូលយ៉ាងសកម្មពីស្ត្រីនៅតាមតំបន់គោលដៅអនុវត្តន៍គម្រោងផងដែរ។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានមន្ត្រីជំនាញ និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការរៀបចំ និងអនុវត្តន៍គម្រោងនេះ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**សកម្មភាពគម្រោងអាចដំណើរទៅបាន៖ (១) មានការគាំទ្រពីថ្នាក់ដឹកនាំក្រសួង (២) មានកញ្ចប់ថវិកាគ្រប់គ្រាន់ និង(៣)មានការចូលរួម និងសហការពីអនុវិស័យជំនាញដែលពាក់ព័ន្ធ។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**ដៃគូអភិវឌ្ឍន៍ដែលមានសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះរួមមាន៖**

**(១) ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ឬស្ថាប័នផ្តល់ជំនួយផ្សេងទៀតដែលអាចគាំទ្រផ្នែកថវិកាក្នុងការអនុវត្តគម្រោង**

**(២) ក្រុមហ៊ុនបច្ចេកវិទ្យា ដែលអាចជួយជាជំនួយការបច្ចេកទេស លើផ្នែក តម្លើងប្រព័ន្ធ ស្តុកទុក និងគ្រប់គ្រងទិន្នន័យ**

**(៣) អង្គភាពដែលជាអនុវិស័យ ថ្នាក់ជាតិ និងក្រោមជាតិ របស់ក្រសួងកសិកម្ម ចូលរួមសហការក្នុងផ្តល់នូវធាតុចូលឬជំនួយបច្ចេកទេសទៅតាមគ្របខ័ណ្ឌ ជំនាញរបស់ខ្លួន។**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្នើ | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 320.0 | 220.0 | 220.0 | 760.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 100.0 | 100.0 | 100.0 | 300.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 200.0 | 100.0 | 100.0 | 400.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 20.0 | 20.0 | 20.0 | 60.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 1,200.0 | 1,000.0 | 1,000.0 | 3,200.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 300.0 | 300.0 | 300.0 | 900.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 600.0 | 400.0 | 400.0 | 1,400.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 300.0 | 300.0 | 300.0 | 900.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 1,520.0 | 1,220.0 | 1,220.0 | 3,960.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| FAO | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| Asian Development Bank | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 1,520.0 | 1,220.0 | 1,220.0 | 3,960.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: